ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ១៧១ ឧវបន.មបជ.សជណ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការត្រួតពិនិត្យផ្ទៀងផ្ទាត់ស៊ីទែនរថយន្តដឹកជញ្ជូនប្រេងឥន្ធនៈសម្រាប់ឆ្នាំ២០២៤

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី ជាម្ចាស់ស៊ីទែនរថយន្តដឹកជញ្ជូនប្រេងឥន្ធនៈ ដែលកំពុងធ្វើអាជីវកម្មដឹកជញ្ជូនប្រេងឥន្ធនៈនៅព្រះរាជាណាចក្រកម្ពុជាទាំងអស់ឱ្យបានជ្រាបថា៖ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ជាអង្គភាពជំនាញនឹងបន្តអនុវត្តការត្រួតពិនិត្យផ្ទៀងផ្ទាត់សម្រាប់ឆ្នាំ២០២៤ ទៅលើសុក្រឹតភាពចំណុះស៊ីទែនរថយន្តដឹកជញ្ជូនប្រេងឥន្ធនៈដែលធ្វើពាណិជ្ជកម្មលើកដំបូងចំពោះស៊ីទែនថ្មី ឬ ស៊ីទែនដែលត្រូវបានជួសជុលរួច និងស៊ីទែនដែលត្រូវបានត្រួតពិនិត្យផ្ទៀងផ្ទាត់រួច និងបាននឹងកំពុងត្រូវប្រើប្រាស់ ហើយនឹងផុតសុពលភាពក្នុងអំឡុងឆ្នាំ២០២៤។ ការត្រួតពិនិត្យផ្ទៀងផ្ទាត់នេះនឹងបង្កើនទំនុកចិត្តរវាងអ្នកផ្គត់ផ្គង់ និងអ្នកទទួលយកចំណុះប្រេងឥន្ធនៈទាំងអស់។

ចំពោះស៊ីទែនរថយន្តដឹកជញ្ជូនប្រេងឥន្ធនៈទាំងឡាយណា ដែលមិនមានការត្រួតពិនិត្យផ្ទៀងផ្ទាត់ និងដាក់ស្លាកសញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នឹងចាត់វិធានការតាមច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា ដូចមានចែងក្នុងជំពូកទី១០ ស្តីពីទោសប្បញ្ញត្តិជាកំហិត។

អាស្រ័យហេតុនេះ សូម ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី ជាម្ចាស់ស៊ីទែនរថយន្តដឹកជញ្ជូនប្រេងឥន្ធនៈទាំងអស់ សហការអនុវត្តកិច្ចការត្រួតពិនិត្យផ្ទៀងផ្ទាត់តាមសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ស្របតាមច្បាប់ និងលិខិតបទដ្ឋាននានាដែលបានកំណត់។ សូម ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី ឬតំណាង មកទំនាក់ទំនងផ្ទាល់នៅការិយាល័យច្រកចេញចូលតែមួយរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលមានទីតាំងនៅមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ផ្លូវជាតិលេខ ៥ សង្កាត់គីឡូម៉ែត្រលេខ ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឬតាមរយៈលេខទូរសព្ទនិងតេឡេក្រាម៖ **០៩៧ ៩៧០ ២០៥៥** និងអ៊ីម៉ែល៖ **owsnmc.misti@yahoo.com** ចាប់ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ (នៅរៀងរាល់ម៉ោងធ្វើការ) ដើម្បីរៀបចំសំណុំឯកសារស្នើសុំត្រួតពិនិត្យផ្ទៀងផ្ទាត់ស៊ីទែនរថយន្តដឹកជញ្ជូនប្រេងឥន្ធនៈរបស់ ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី ហើយត្រូវបង្កលក្ខណៈងាយស្រួលដល់ការបំពេញភារកិច្ចរបស់មន្ត្រីត្រួតពិនិត្យ និងលក្ខខណ្ឌតម្រូវនានាដែលពាក់ព័ន្ធនឹងបច្ចេកទេស។

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សង្ឃឹម និងជឿជាក់ថា ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី ជាម្ចាស់ស៊ីទែនរថយន្តដឹកជញ្ជូនប្រេងឥន្ធនៈទាំងអស់នឹងយកចិត្តទុកដាក់ និងសហការអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះ ឱ្យមានប្រសិទ្ធភាព ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ សុក្រ ១រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែមករា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**ហេម វណ្ណឌី**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
  "ដើម្បីគោរពជូនជ្រាប"
- រដ្ឋបាលរាជធានី-ខេត្ត
  "ដើម្បីសហការអនុវត្ត"
- គ្រប់មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានី-ខេត្ត
  "ដើម្បីផ្សព្វផ្សាយបន្ត និងសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ: (៨៥៥)-២៣-២១១១៤១
45 Preah Norodom Boulevard, Sangkat Phsar Thmey III, Khan Daun Penh, Phnom Penh, Phone: (855)-23-211141